ក្រសួងសុខាភិបាល

unicef for every child

World Health Organization
Representative Office for Cambodia

# សេចក្តីប្រកាសព័ត៌មាន

## ព្រះរាជាណាចក្រកម្ពុជា ស្ថិតក្នុងចំណោមប្រទេសដំបូងគេ ដែលទទួលបានវ៉ាក់សាំងកូវីដ-១៩ AstraZeneca/SII ពីយន្តការ COVAX

នាថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ វ៉ាក់សាំង AstraZeneca/SII ចំនួន ៣២៤.000 ដូស នឹងមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងត្រូវបានដឹកជញ្ជូនទៅរក្សាទុក នៅឃ្លាំងឱសថកណ្តាលរបស់ក្រសួងសុខាភិបាល មុនពេលផ្តល់ជូនក្រុមពលរដ្ឋអាទិភាព ដូចជាក្រុមដែលប្រឈមខ្ពស់នឹងការឆ្លងមេរោគកូវីដ-១៩ និងអ្នកងាយធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារមេរោគនេះ។ វ៉ាក់សាំងកូវីដ-១៩ បន្ថែមទាំងនេះនឹងផ្តល់ឱ្យរាជរដ្ឋាភិបាលកម្ពុជានូវមធ្យោបាយដ៏មានអនុភាពមួយទៀត ក្នុងការបន្តកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩។

ទោះជាយ៉ាងនេះក្តី វ៉ាក់សាំងតែមួយមុខនឹងមិនអាចបញ្ចប់ការឆ្លងរាតត្បាតជាសកលនៃជំងឺនេះឡើយ។ ការបន្តអនុវត្តវិធានការសុខភាពសាធារណៈ ដើម្បីទប់ស្កាត់ការចម្លងជំងឺនេះ នៅតែចាំបាច់ ដូចជាការធ្វើតេស្ត ការគោរពវិធានការចត្តាឡីស័ក ការពាក់ម៉ាស់ ការលាងសម្អាតដៃ និងការរក្សាគម្លាតសុវត្ថិភាពជាដើម។

វ៉ាក់សាំងចំនួន ៣២៤.000 ដូស គឺជាចំនួនដូសមកដល់ដំបូង ក្នុងចំណោមវ៉ាក់សាំងសរុបចំនួន ១,១ លានដូស ដែលយន្តការ COVAX នឹងផ្តល់ជូនប្រទេសកម្ពុជាជាដំណាក់កាលនៅត្រឹមបំណាច់ខែឧសភា។ ប្រទេសកម្ពុជា ត្រូវបានរំពឹងទុកថានឹងទទួលបានបរិមាណវ៉ាក់សាំងសម្រាប់ ២០% នៃប្រជាពលរដ្ឋសរុប (ប្រហែល ៧លានដូស) ពីយន្តការ COVAX ដែលនឹងដឹកជញ្ជូនមកជាបន្តបន្ទាប់នៅក្នុងឆ្នាំនេះ។ យន្តការCOVAX គឺជាកិច្ចខិតខំជាសកលដែលមិនធ្លាប់មានពីមុនមក ដើម្បីផ្តល់ឱ្យប្រទេសទាំងអស់នៅក្នុងពិភពលោក នូវសមភាពទទួលបានវ៉ាក់សាំងប្រកបដោយសុវត្ថិភាព ដើម្បីការពារជំងឺកូវីដ-១៩ ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ យន្តការ COVAX គឺជាកម្មវិធីដឹកនាំដោយ Gavi CEPI និងអង្គការ

សុខភាពពិភពលោក (WHO) សហការជាមួយយូនីសេហ្វ។ កម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសដំបូងៗគេនៅក្នុងតំបន់ប៉ាស៊ីហ្វិកខាងលិច ដែលទទួលបានវ៉ាក់សាំងពីយន្តការ COVAX ។

ដោយសារការផ្គត់ផ្គង់វ៉ាក់សាំងនៅទូទាំងសកលលោកមានកម្រិត រាជរដ្ឋាភិបាលកម្ពុជាកំពុងធ្វើលទ្ធកម្មវ៉ាក់សាំងតាមរយៈមធ្យោបាយជាច្រើន ដែលបំពេញទៅតាមស្តង់ដាសុវត្ថិភាព ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ដើម្បីការពារប្រជាពលរដ្ឋ។ ការចាក់វ៉ាក់សាំងដំបូងបង្អស់ត្រូវបានធ្វើឡើងកាលពីថ្ងៃទី១០ ខែកុម្ភៈ ហើយគិតមកដល់ពេលនេះ មានមនុស្សជាង ៦៥.០០០ នាក់បានចាក់វ៉ាក់សាំង។ ការមកដល់នៃវ៉ាក់សាំងបន្ថែមនេះ គឺជាជំហានដ៏សំខាន់មួយទៀត ឆ្ពោះទៅគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងចាក់វ៉ាក់សាំងដល់ប្រជាពលរដ្ឋឱ្យបាន ១០លាននាក់។

ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ថា "នៅដំណាក់កាលដំបូងៗនៃការចាប់ផ្តើមយុទ្ធនាការចាក់វ៉ាក់សាំងនេះ អាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា គឺសង្គ្រោះជីវិត តាមរយៈការការពារបុគ្គលិកសុខាភិបាលជួរមុខ អ្នកដែលប្រឈមខ្ពស់ទៅនឹងការឆ្លងជំងឺកូវីដ ១៩ ឬអ្នកដែលងាយនឹងធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារតែមេរោគកូវីដ-១៩។ នេះគឺជាវិធីសាស្ត្រដ៏ល្អបំផុត ដើម្បីប្រើប្រាស់វ៉ាក់សាំងដែលបរិមាណផ្គត់ផ្គង់នៅមានកម្រិត ក្នុងគោលបំណងសម្រេចឱ្យបានលទ្ធផលជាអតិបរមានៅដំណាក់កាលដំបូងនេះ។ វ៉ាក់សាំងមិនត្រឹមតែជួយជីវិតប៉ុណ្ណោះទេ វាក៏ជួយពន្លឿនការស្តារសេដ្ឋកិច្ចប្រទេសឡើងវិញផងដែរ"។

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល ក៏បានមានប្រសាសន៍ផងដែរថា "ខ្ញុំសូមទទូចឱ្យអ្នកគ្រប់គ្នាបន្តអនុវត្តតាមគោលការណ៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** អំពីវិធីការពារខ្លួន ៣ការពារ និង៣កុំ។ វិធីការពាររួមមាន ពាក់ម៉ាស់ លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាព១,៥ម៉ែត្រ ហើយសកម្មភាពគួរជៀសវាងទាំងបីរួមមាន កុំទៅ កន្លែងបិទជិត កន្លែងមានមនុស្សកុះករ និងកុំប៉ះពាល់គ្នាជាដើម។ សូមនៅផ្ទះប្រសិនបើអ្នកមានជំងឺ គ្រុនក្តៅ ឬសង្ស័យថាបានឆ្លងជំងឺកូវីដ-១៩ និងសូមស្វែងរកជំនួយសុខាភិបាលភ្លាមៗ ឬទូរសព្ទទៅលេខ ១១៥។"

បើតាមផែនការជាតិស្តីពីការផ្តល់ និងការចាក់វ៉ាក់សាំងរបស់កម្ពុជា (NDVP) ក្រុមអាទិភាពរួមមាន បុគ្គលិកសុខាភិបាល និងបុគ្គលិកបំពេញការងារសំខាន់ចាំបាច់ ដែលកំពុងចូលរួមក្នុងយុទ្ធនាការចាក់វ៉ាក់សាំង ពលរដ្ឋចាស់ជរា និងមនុស្សពេញវ័យដែលមានជំងឺប្រចាំកាយជាដើម។ ដោយសារតែការផ្គត់ផ្គង់វ៉ាក់សាំងនៅមានកម្រិត ព្រោះតែតម្រូវការខ្ពស់នៅទូទាំងសកលលោក ការចាក់វ៉ាក់សាំងដល់ក្រុមអាទិភាពទាំងនេះ នឹងធ្វើឡើងជាបណ្តើរៗ និងជាដំណាក់កាលៗ។ រាជរដ្ឋាភិបាលនឹងធ្វើការអប់រំ

ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋទូទៅ ដើម្បីផ្តល់ព័ត៌មានបច្ចុប្បន្នភាពដល់ប្រជាពលរដ្ឋ សំដៅឱ្យក្រុមអាទិភាព ទទួលបានព័ត៌មានថ្មីៗបំផុតអំពីរបៀបទទួលបានវ៉ាក់សាំង និងពេលវេលា នៅពេលដល់វេនពួកគេ។

ការអភិវឌ្ឍវ៉ាក់សាំងដែលមានប្រសិទ្ធភាព និងសុវត្ថិភាព ក្នុងរយៈពេលមិនដល់មួយឆ្នាំ បន្ទាប់ពីការផ្ទុះឡើងនៃមេរោគនេះ គឺជាភាពជោគជ័យមួយ ក្នុងចំណោមភាពជោគជ័យដ៏អស្ចារ្យជាងគេ ក្នុងវិស័យវេជ្ជសាស្ត្រទំនើប។ វ៉ាក់សាំងដែលនឹងត្រូវប្រើនៅកម្ពុជាសុទ្ធតែបានឆ្លងកាត់នីតិវិធីអភិវឌ្ឍន៍ និងការធ្វើតេស្តសុវត្ថិភាពដ៏តឹងរ៉ឹងដោយរដ្ឋាភិបាលបានធ្វើការវាយតម្លៃលើភស្តុតាង អត្ថប្រយោជន៍ និងហានិភ័យនានាដែលពាក់ព័ន្ធ។ វ៉ាក់សាំង AstraZeneca/SII ដែលផ្តល់ដោយយន្តការ COVAX បានទទួលការអនុញ្ញាតឱ្យប្រើប្រាស់នៅក្នុងស្ថានភាពបន្ទាន់ ពីក្រសួងសុខាភិបាល កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ ក្រោយពេលដែលអង្គការសុខភាពពិភពលោក អនុញ្ញាតឱ្យប្រើប្រាស់សម្រាប់ស្ថានភាពបន្ទាន់កាលពីថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២១ ។

លោកស្រីវេជ្ជបណ្ឌិត លី អៃឡាន តំណាងអង្គការសុខភាពពិភពលោកនៅកម្ពុជា បានមានប្រសាសន៍ថា "អង្គការសុខភាពពិភពលោក កំពុងធ្វើការងារយ៉ាងជិតស្និតជាមួយនឹង Gavi CEPI និងយូនីសេហ្វ ដើម្បីធានាឱ្យមានការទទួលបានវ៉ាក់សាំង ប្រកបដោយយុត្តិធម៌ និងសមធម៌។ យើងមានមោទនភាពដែលបានចូលរួមបំពេញការងារក្នុងស្ថានភាពដ៏ពិសេសនេះ។ បន្ថែមលើការអនុវត្តវិធានការសុខភាពសាធារណៈ វ៉ាក់សាំងកូវីដ-១៩ គឺជាឧបករណ៍ថ្មីមួយទៀតដ៏សំខាន់ សម្រាប់ការពារប្រជាពលរដ្ឋ ការពារប្រព័ន្ធសុខាភិបាល មិនឱ្យរងសម្ពាធខ្លាំងពេក និងជួយសង្គ្រោះជីវិតមនុស្ស។"

បន្ថែមលើកិច្ចសហការក្នុងការផ្តល់វ៉ាក់សាំងតាមរយៈយន្តការ COVAX រាជរដ្ឋាភិបាលកម្ពុជាបានសហការយ៉ាងជិតស្និតជាមួយនឹងអង្គការសុខភាពពិភពលោក និងយូនីសេហ្វ ដើម្បីរៀបចំយុទ្ធសាស្ត្រពង្រីកនូវសមត្ថភាព និងវិសាលភាពនៃការផ្តល់វ៉ាក់សាំងកូវីដ-១៩ ។

លោកស្រី ហ្វ័រហ្គ ហ្វយូហ្សិថ តំណាងអង្គការយូនីសេហ្វប្រចាំកម្ពុជា បានមានប្រសាសន៍ថា "យូនីសេហ្វមានមោទនភាព ដែលបាន និងកំពុងសហការជាមួយនឹងក្រសួងសុខាភិបាល និងអង្គការសុខភាពពិភពលោក ក្នុងការផ្តល់វ៉ាក់សាំងនៅកម្ពុជាអស់កាលជាយូរឆ្នាំមកហើយ។ វ៉ាក់សាំងថ្មីនេះនឹងបង្កើតឱកាសដ៏សំខាន់មួយ ដើម្បីផ្លាស់ប្តូរទិសដៅនៃការឆ្លងរាលដាលជាសកលនេះ។ ដោយសារតែបុគ្គលិកសុខាភិបាល និងបុគ្គលិកជួរមុខដទៃទៀត នឹងទទួលបានវ៉ាក់សាំង យើងនឹងអាចមើលឃើញជាបណ្តើរៗនូវការវិលទៅ

រកជីវិតជាប្រក្រតីតាមគន្លងថ្មី រួមទាំងការទទួលបានសេវាសុខភាព ការអប់រំ និងការការពារកាន់តែប្រសើរ។ ស្របតាមស្មារតីពង្រីកការគ្របដណ្តប់សេវាសុខភាពជាសកល យើងមិនត្រូវទុកអ្នកណាម្នាក់ចោលឡើយ។"

ផ្អែកតាមភស្តុតាងដែលមានបច្ចុប្បន្ននេះ យើងដឹងថាវ៉ាក់សាំងកូវីដ-១៩ អាចការពារមនុស្សពីការធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរនៅពេលឆ្លងជំងឺនេះ និងកាត់បន្ថយរយៈពេលព្យាបាលនៅក្នុងមន្ទីរពេទ្យ។ បើទោះជាមនុស្សបានចាក់វ៉ាក់សាំងក៏ដោយ ពួកគេគួរបន្តអនុវត្តតាមវិធានការការពារនានាដូចជារក្សាគម្លាតសុវត្ថិភាព ពាក់ម៉ាស់ និងលាងសម្អាតដៃជាដើម។ យើងត្រូវបំពេញភារៈកិច្ចរបស់យើងរៀងៗខ្លួន ក្នុងការប្រើប្រាស់វិធីសាស្ត្រនិងឧបករណ៍ទាំងអស់ដែលមាន ដើម្បីយកឈ្នះការឆ្លងរាលដាលជាសកលនៃជំងឺនេះ។

**សម្រាប់ព័ត៌មានបន្ថែម៖**

ឯកឧត្តម វេជ្ជបណ្ឌិត ស៊ុង វិនត:
ទីប្រឹក្សា និងប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងសុខាភិបាល
ទូរស័ព្ទ៖ ០៧៧ ៩៣៩ ៥៩៨

លោកឱសថការី ឱក វិជិត
អនុប្រធានមជ្ឈមណ្ឌលជាតិគាំពារសុខភាពមាតានិងទារក និងជាប្រធានកម្មវិធីជាតិផ្តល់ថ្នាំបង្ការ
ទូរស័ព្ទ៖ ០១២ ៨៣០ ៥៤៨